# ទេវវិទ្យាក្នុងព្រះពុទ្ធសាសនា
## THEOLOGY IN BUDDHISM

សាសនាភាគច្រើននៅក្នុងលោកយើងនេះ រមែងមានជំនឿងនិងការបដិបត្តិទាក់ទងនឹងទេវៈទាំងឡាយ ។ ជំនឿងនិងការបដិបត្តិទាំងនោះ ជួនកាលមានភាពខុសគ្នាដោយជំរៅនិងការបដិបត្តិជាច្រើន ។ តែយើងអាចបែងប្រភេទសាសនានៅក្នុងលោកយើងនេះបានជាពីរធំៗគឺ សាសនាបែបទេវនិយម theism និងសាសនាបែបអទេវនិយម atheism ។ សាសនាបែបទេវនិយមមានដូចជា ព្រហ្មញ្ញសាសនា សាសនាយិវ សាសនាគ្រីស្ត សាសនាអ៊ីស្លាម សាសនាសិក និងសាសនាសូរូអាស្ទើរ ។ ចំណែកព្រះពុទ្ធសាសនាអ្នកប្រាជ្ញទាំងឡាយចាត់ទុកថា ជាសាសនាបែបអទេវនិយម ។ តាមពិត សេចក្តីពិតគឺដូច្នោះ ។ ព្រះសម្មាសម្ពុទ្ធទ្រង់លើកសរសើរនូវសក្តានុពលរបស់ភាពជាមនុស្សថា ខ្ពង់ខ្ពស់ជាងពពួកសត្វឬទេវៈក្នុងភពទាំងឡាយ ។ភាពជាមនុស្សដែលមានឧត្តគតិការព្យាយាមខ្ពស់ និងប្រកបដោយសម្មាទិដ្ឋិតាមគន្លងព្រះអរិយមគ្គប្រកបដោយអង្គ៨ ច្បាស់ជាបានសំរេចនូវសម្បត្តិមនុស្ស សម្បត្តិទេវលោក និងព្រះនិព្វានជាក់ជាមិនខាន ។ ទោះជាយ៉ាងណាក៏ដោយ ទេវវិទ្យាក្នុងព្រះពុទ្ធសាសនា មានលក្ខណៈទូលំទូលាយនិងគួរអោយចង់សិក្សាយ៉ាងខ្លាំង ។

### ត្រៃលោក គឺវាលវដ្តសង្សាររបស់សត្វលោកទាំងឡាយ
(Three Worlds are the Recycling State of all Creatures)

ត្រៃលោកមានន័យថាលោកទាំងបី គឺកាមលោក រូបលោក និងអរូបលោក ។ ពាក្យថាលោកអាចមានន័យស្មើនឹងពាក្យថា ឋាន ដែលភាសាអង់គ្លេសអាចជា dimension, realm, state ។ លោកទាំងបីនេះ បែងជា ៣១ ឋានឬភព គឺកាមភព មាន១១ ជាន់, រូបភព មាន១៦ជាន់ និងអរូបភព មាន៤ ជាន់ ។

១. កាមភព (Planes of sensuous bliss) គឺជាភពដែលនៅបរិភោគទៅដោយកាមគុណទាំងឡាយ៥គឺរូប ខ្លិន រស សម្ផស្ស និងសំលេង ។ កាមភពនេះបែងទៅតាមអំណាចនៃកម្មដែលមនុស្សបានធ្វើអំពើជាកុសលនិងអំពើជាអកុសល ។ បើធ្វើអំពើជាកុសល នឹងបានទៅកើតក្នុងឋានទាំងនេះគឺ

- មនុស្សលោក (human realm)ដែលយើងទាំងអស់គ្នារស់នៅបច្ចុប្បន្ននេះ មានអាយុខ្ពស់បំផុតត្រឹម៧៥ទៅ៨0 ជាមធ្យម ហើយអស់បុណ្យស្លាប់ទៅ ។
- ទេវលោក ៦ ជាន់ទៀតគឺ

ជាន់ទី១- ចាតុមហារាជកា (realm of the Four Great Kings)ជាទេវលោកថ្នាក់ទាបជាងគេបំផុត មានអាយុ៥00 ឆ្នាំទិព្វ គិតជាឆ្នាំមនុស្សស្មើនឹង ៩ លានឆ្នាំ ។

ជាន់ទី២- តាវតឹង្សា (realm of the Thirty-three Gods)ជាទេវលោកថ្នាក់ទាបបន្ទាប់ទៀត មានអាយុ១ពាន់ឆ្នាំទិព្វ គិតជាឆ្នាំមនុស្សបាន៣កោដិ ៦លានឆ្នាំ ។

ជាន់ទី៣- យាមា (realm of the Yaama gods) មានអាយុ២ពាន់ឆ្នាំទិព្វ គិតជាឆ្នាំមនុស្សបាន១៤កោដិ ៤លានឆ្នាំ ។
ជាន់ទី៤- តុសិត (realm of satisfied gods) មានអាយុ៤ពាន់ឆ្នាំទិព្វ គិតជាឆ្នាំមនុស្សបាន៥៧កោដិ ៦លានឆ្នាំ ។
ជាន់ទី៥- និម្មានរតី (realm of the gods who rejoice in their own creation) មានអាយុ៨ពាន់ឆ្នាំទិព្វ គិតជាឆ្នាំមនុស្សបាន២៣០កោដិ ៤លានឆ្នាំ ។
ជាន់ទី៦- បរនិម្មិតវសវត្តី (realm of gods who lord over the creation of others) មានអាយុ១ម៉ឺន ៦ពាន់ឆ្នាំទិព្វ គិតជាឆ្នាំមនុស្សបាន៩២១កោដិ ៦លានឆ្នាំ ។

ចំណែកអំពើដែលជាអកុសលនឹងនាំសត្វអោយទៅកើតក្នុងអបាយភូមិ (Planes of loss or woe or unhappy planes) មាន ៤ គឺ

១. នរក (woeful state; hell) គឺភពដែលមនុស្សត្រូវទៅសោយទុក្ខវេទនា ព្រោះខ្លួនបានធ្វើបាបកម្មច្រើនក្នុងឋានមនុស្សឬអស់បុណ្យពីឋានទេវតា ។ អន្លង់នរកដែលជ្រៅជាងគេគឺអសញ្ញីអវចីនរក ព្រោះតែបាន ប្រព្រឹត្តនូវអនន្តរិយកម្ម ៥យ៉ាង មានការសំលាប់មាតា សំលាប់បីតា ធ្វើសង្ឃភេទ ធ្វើលោហិតព្រះពុទ្ធឱ្យធ្លាក់ចុះជាដើម ។

២. ប្រេត (ghost-sphere) គឺភពដែលមានសេចក្តីស្រេកឃ្លានខ្លាំង

៣. អសុរកាយ (host of demons) គឺពភដែលមានកាយមិនស្អាត ប្រកបដោយក្លិនស្អុយគ្រគ្រក់

៤. តិរច្ឆាន (animal kingdom) គឺភពសត្វធាតុទាំងឡាយ មានសត្វចតុបាទ ទ្វេរបាទ សត្វលូន សត្វហើរជាដើម

២. រូបភព សំដៅយករូបព្រហ្មឬព្រហ្មមានរូប ១៦ ជាន់គឺ

ជាន់ទី១- បារិសជ្ជា (realm of great Brahmas'attendants) ពួកព្រហ្មមានអាយុមួយចំណែកកប្ប (កប្បមួយចែកជាបីចំណែក) ។
ជាន់ទី២- បុរោហិតា (realm of great Brahmas'ministers) ពួកព្រហ្មមានអាយុកន្លះកប្ប
ជាន់ទី៣- មហាព្រហ្មា (realm of great Brahmas) ពួកព្រហ្មមានអាយុមួយកប្ប
ជាន់ទី៤- បរិត្តាភា (realm of Brahmas with limited lustre) ពួកព្រហ្មមានអាយុ២កប្ប
ជាន់ទី៥- អប្បមាណាភា (realm of Brahmas with infinite lustre) ពួកព្រហ្មមានអាយុ៤កប្ប
ជាន់ទី៦- អាភស្សរា (realm of Brahmas with radiant lustre) ពួកព្រហ្មមានអាយុ ៨ កប្ប
ជាន់ទី៧- បរិត្តសុភា (realm of Brahmas with limited aura) ពួកព្រហ្មមានអាយុ ១៦ កប្ប
ជាន់ទី៨- អប្បមាណសុភា (realm of Brahmas with infinite aura) ពួកព្រហ្មមានអាយុ ៣២ កប្ប
ជាន់ទី៩- សុភកិណ្ហា (realm of Brahmas with steady aura) ពួកព្រហ្មមានអាយុ ៦៤ កប្ប
ជាន់ទី១០- វេហប្ផលា (realm of Brahmas with abundant reward) ពួកព្រហ្មមានអាយុ ៥០០ កប្ប

ជាន់ទី១១- អសញ្ញីសត្វ (realm of non-percipient beings) ពួកព្រហ្មមានអាយុ ៥០០ កប្ប

ជាន់ទី១២- អវិហា (realm of Brahmas who do not fall from prosperity) ពួកព្រហ្មមានអាយុ ១០០០ កប្ប

ជាន់ទី១៣- អតប្បា (realm of Brahmas who are serene) ពួកព្រហ្មមានអាយុ ២ ពាន់កប្ប

ជាន់ទី១៤- សុទស្សា (realm of Brahmas who are beautiful) ពួកព្រហ្មមានអាយុ ៤ ពាន់កប្ប

ជាន់ទី១៥- សុទស្សី (realm of Brahmas who are clear-sighted) ពួកព្រហ្មមានអាយុ ៨ ពាន់កប្ប

ជាន់ទី១៦- អកនិដ្ឋា (realm of the highest or supreme Brahmas) ពួកព្រហ្មមានអាយុ ១ម៉ឺន ៦ពាន់កប្ប

២. អរូបព្រហ្ម គឺព្រហ្មឥតរូប មាន៤ជាន់គឺ

ជាន់ទី១- អាកាសានញ្ចាយតនៈ (realm of infinite space) ពួកព្រហ្មមានអាយុ ២ ម៉ឺនកប្ប

ជាន់ទី២- វិញ្ញាណញ្ចាយតនៈ (realm of infinite consciousness) ពួកព្រហ្មមានអាយុ ៤ ម៉ឺនកប្ប

ជាន់ទី៣- អកិញ្ចញ្ញាយតនៈ (realm of nothingness) ពួកព្រហ្មមានអាយុ ៦ ម៉ឺនកប្ប

ជាន់ទី៤- នេវសញ្ញានាសញ្ញាយតនៈ (realm of neither perception nor non-perception)ពួកព្រហ្មមានអាយុ ៨ ម៉ឺន ៤ ពាន់កប្ប ។

ឋានសួគ៌ាជាន់ផ្សេងៗទាំងនេះ ព្រះពុទ្ធជាម្ចាស់បានបញ្ជាក់យ៉ាងច្បាស់អំពីវិធីបដិបត្តិទៅឱ្យដល់ឋានសួគ៌ាជាន់នីមួយៗ និងអាយុកាលរបស់ឋានសួគ៌ជាន់នីមួយៗយ៉ាងលំអិត។ ដូច្នេះព្រះពុទ្ធជាម្ចាស់ទទួលស្គាល់នូវសេចក្តីមានពិតប្រាកដរបស់ឋានសួគ៌ទាំងអស់នោះ ប៉ុន្តែមិនមែនជាបរមសុខពិតប្រាកដរបស់មនុស្សទេ មានតែព្រះនិព្វានទេដែលជាបរមសុខរបស់មនុស្ស ។

## មនុស្សលោកយើងកើតពីវិវឌ្ឍនាការដ៏យូរលង់

(Our earth was created by the uncalculated evolution period)

នៅក្នុងគម្ពីរអគ្គញ្ញសូត្រ ព្រះពុទ្ធអង្គទ្រង់សំដែងអំពីកំណកំណើតផែនដីយើងថា ពិភពលោកយើងនេះកាលដើមឡើយជាសុញ្ញកាសដែលគ្មានអ្វីទាំងអស់( អវិជ្ជា) ក្រោយមកទើបមានភ្លៀងធ្លាក់ ហើយមានខ្យល់បក់ មានរលកបក់បោកយ៉ាងខ្លាំង ធ្វើឱ្យពពុះទឹកបានក្លាយទៅជាដី ដែលដីនេះមានរស់ជាតិឆ្ងាញ់ខុសធម្មតា ធ្វើឱ្យពពួកអភស្សរាព្រហ្មជាប់រស់ជាតិដីនេះ កើតសេចក្តីលោភលន់ ហើយក៏អស់ឈានសមាបត្តិទៅ។ យ៉ាងណាក៏ដោយ នៅពេលដែលធាតុធំៗទាំងបួន គឺ ទឹក ខ្យល់ ដី និង ភ្លើង មានគ្រប់គ្រាន់ ទើបមានរុក្ខជាតិ ហើយសត្វមានជីវិតក៏កកើតឡើងលើផែនដីយើងនេះ។ ការដែលមានភ្លៀងមាន ខ្យល់ រហូតក្លាយ ជាដី ជាភ្លើង ត្រូវប្រើរយះពេលរាប់លានឆ្នាំតាមហេតុបច្ច័យនៃទ្រឹស្តីវិវឌ្ឍនាការ ទើបក្រោយមក មានរុក្ខជាតិ សត្វ និងមនុស្សកើតឡើងនៅលើលោកយើងនេះ ។

## វិវឌ្ឍនាការផែនដីតាមកប្បនីមួយៗ

(The evolution of our earth following each Kappa period)

ព្រះពុទ្ធសាសនាបានបែងចែកអាយុចក្រវាឡយើងនេះជាកប្ប ដោយមួយកប្បៗជារង្វិលមួយជុំនៃការកើតនិងការរលាយនៃផែនដី ។ ការកំណត់នេះគិតទៅតាមរយៈកាលដែលគ្មានភ្លៀងធ្លាក់នៅលើផែនដីយើងនេះ ហើយផែនដីយើងនេះក្តៅរហូតដល់ភ្លើងឆេះកប្បរលាយបាត់ទៅ ។ ព្រះពុទ្ធជាម្ចាស់បែងចែកពិភពចក្រវាឡយើងនេះជា៤កប្បធំៗគឺ

១. សំវត្តកប្ប(samvatta-kappa) ពិភពចក្រវាឡយើងនេះ ដំណាក់កាលដំបូងឈ្មោះថា សំវត្តកប្បដែលកប្បនេះស្ថិតនៅរវាងដំណាក់កាលមានភ្លៀងបង្អុរ និងដំណាក់កាលមានព្រះអាទិត្យរះរហូតដល់ទៅ ៧។ ធ្វើឱ្យពិភពចក្រវាឡទាំងមូលឡើងក្តៅយ៉ាងខ្លាំង ឆេះពិភពចក្រវាឡអស់រហូតរលាយសោះសូន្យជាសុញ្ញកាស( អវិជ្ជា) នៅទីបំផុត ។ ព្រះអង្គបញ្ជាក់ថាជាកប្បដែលមានភាពវឹកវរ និងរលំរលាយយ៉ាងខ្លាំង ។

២. សំវត្តដ្ឋាយិកប្ប(samvattatthaayi-kappa) កប្បទីពីរដែលត្រូវបានគេស្គាល់ថា សំវត្តដ្ឋាយិកប្ប ដែលជាកប្បមួយដែលពេលឋានសួគ៌និងផ្ទៃមេឃ គ្របដណ្តប់ទៅដោយល្អងធូលីនិងភាពងងឹតសូន្យសុង ។ ដំណាក់កាលនេះត្រូវបានគេទទួលស្គាល់ថាជាពេលវឹកវរនិងសាបសូន្យបន្តពីកប្បទីមួយ ។

៣. វិវត្តកប្ប (vivatta-kappa) ដំណាក់កាលទីបីឈ្មោះថាវិវត្តកប្ប ដែលរាប់ចាប់ផ្តើមពីពេលដែលមានភ្លៀងធ្លាក់វិវឌ្ឍន៍ទាល់តែមានព្រះអាទិត្យនិងព្រះចន្ទកើតឡើង ។ រយៈពេលនេះ មានវិវឌ្ឍនាការរាប់លានឆ្នាំមិនអាចគណនាបានឡើយ ។

៤. វិវត្តដ្ឋាយិ (vivattatthaayi-kappa) ដំណាក់កាលទីបួនឈ្មោះថាវិវត្តដ្ឋាយិ ដែលកប្បនេះចាប់ផ្តើមនៅពេលដែលព្រះអាទិត្យនិងព្រះចន្ទផុះឡើងតាមល្អងធុលី វិវឌ្ឍន៍អស់រយៈពេលដ៏យូររហូតដល់ដំណាក់កាលវិនាសសាបសូន្យនៃទឹកភ្លៀង ។

## ឯកសារយោង


១. សោម ងន, ពន្លឺពុទ្ធសាសនា, អុស្សៀនសាយ, កាលីហ្វញ៉ា, ២០០២

២. សុត្តន្តបិដក, ទីឃនិកាយ, បាទិកវគ្គ:

៣. សុត្តន្តបិដក, មជ្ឈិមនិកាយ, មូលបណ្ណាសកៈ

៤. សុត្តន្តបិដក, អង្គុត្តរនិកាយ, នវកោវាទ

2. Radhika Abeysekera, Practicing the Dhamma with a view to Nibbaana, The corporate Body of the Buddha Educational Foundation, May 2002

3. P.A.Payuttho, Dictionary of Buddhism, Mahachulalongkorn University, Bangkok, B.E.238